**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មហានគរ ម.ក**

**MOHANOKOR Microfinance Institution Plc.**

# ដំណឹងជ្រើសរើសបុគ្គលិក

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មហានគរ ម.ក** គឺជាគ្រឹះស្ថានឯកជន ដែលផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដល់ប្រជាជនកម្ពុជា ជាមួយនឹងតំបន់ប្រតិបត្តិការទូទាំង ២៥ខេត្តក្រុង និងរាជធានី ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ ។ ឆ្លើយតបទៅនឹងការរីកចម្រើនជាបន្តបន្ទាប់ គ្រឹះស្ថានត្រូវការជ្រើសរើស **នាយកសាខា (Branch Manager)** ចំនួន **០១ នាក់** សម្រាប់បម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មហានគរ ម.ក **សាខាខេត្តបន្ទាយមានជ័យ** ។

## តួនាទី និងភារកិច្ចទទួលខុសត្រូវ

- គ្រប់គ្រង និងដឹកនាំប្រធានជំនាញទាំងអស់ សិក្សាស្វែងយល់ឱ្យបានច្បាស់លាស់នូវរាល់ខ្លឹមសារគោលការណ៍ នីតិវិធីពាក់ព័ន្ធនឹងការងារ រួមទាំងគំនិតថ្មីៗ ដើម្បីស្នើ ឬឆ្លងយោបល់ ជូនទៅថ្នាក់គ្រប់គ្រងផ្ទាល់ ដើម្បីអនុវត្តន៍ឱ្យបានត្រឹមត្រូវ និងអភិវឌ្ឍន៍ទាន់សម័យកាលជានិច្ចក្នុងតួនាទី។
- ដាក់ចេញនូវផែនការយុទ្ធសាស្រ្តការងារ រៀបចំចាត់ចែងការងារជូនតាមផ្នែកជំនាញតាមតួនាទីភារកិច្ចទទួលខុសត្រូវខ្ពស់ស្របតាមទំហំការងារ។
- ដឹកនាំការងារ និងលើកទឹកចិត្តនិយោជិត ឱ្យអនុវត្តន៍ការងារប្រកបដោយប្រសិទ្ធភាព តម្លាភាព និងការទទួលខុសត្រូវខ្ពស់។
- ដឹកនាំគ្រប់គ្រងប្រតិបត្តិការសាខា ដើម្បីសម្រេចឲ្យបាននូវកិច្ចការដូចខាងក្រោម៖
  - កិច្ចការធនធានមនុស្ស, បណ្តុះបណ្តាល និងកិច្ចការរដ្ឋបាល
  - កិច្ចការទីផ្សារ, ឥណទាន, ប្រាក់សន្សំ-បញ្ញើ និងសេវាហិរញ្ញវត្ថុផ្សេងៗ
  - កិច្ចការគ្រប់គ្រងសាច់ប្រាក់, គណនេយ្យ និងហិរញ្ញវត្ថុ
  - កិច្ចការច្បាប់
- កិច្ចការផ្សេងៗ ទៀតតម្រូវដោយអ្នកគ្រប់គ្រង

## លក្ខខណ្ឌនៃការជ្រើសរើស

- កម្រិតអនុបណ្ឌិត ឬបរិញ្ញាបត្រជំនាញ ធនាគារ និងហិរញ្ញវត្ថុ សេដ្ឋកិច្ចអាជីវកម្ម ឬជំនាញពាក់ព័ន្ធផ្សេងទៀត។
- មានបទពិសោធន៍យ៉ាងតិច ០២ឆ្នាំ ពាក់ព័ន្ធនឹងកិច្ចការគ្រប់គ្រង ។
- មានការបង្កើតស្នាដៃថ្មីៗ ភាពលេចធ្លោ សមត្ថភាពគ្រប់គ្រង និងផលិតភាពការងារបានល្អប្រសើរ។
- មានភាពវៃឆ្លាត គំនិតឆ្នៃប្រឌិតខ្ពស់ មានការវិភាគជ្រៅជ្រះ។
- មានចំណេះដឹងខាងផ្នែកបច្ចេកទេសដូចជា Ms. Word, Excel, Powerpoint, Email, …។
- មានទំនាក់ទំនងល្អគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធ និងបង្កើនភាពទុកចិត្ត។
- មានភាពស្មោះត្រង់ សុខភាពល្អ មានឆន្ទៈខ្ពស់ចំពោះការងារ មានភាពអត់ធ្មត់ ផែនការទិសដៅនិងចក្ខុវិស័យ។

## អត្ថប្រយោជន៍ទទួលបាន

- ប្រាក់បៀវត្សខ្ពស់ និងប្រកួតប្រជែងជាមួយទីផ្សារការងារបច្ចុប្បន្ន
- ប្រាក់ជួលម៉ូតូ និងឧបត្ថម្ភសាំងប្រចាំខែ
- ប្រាក់រង្វាន់លើកទឹកចិត្តប្រចាំខែ
- វិភាជន៍ប្រាក់ចំណេញប្រចាំឆ្នាំ
- ប្រាក់ឧបត្ថម្ភលើការសិក្សាជំនាញ
- ការបណ្តុះបណ្តាលជំនាញបន្ថែម
- ប្រាក់ឧបត្ថម្ភតំបន់
- ប្រាក់ឧបត្ថម្ភលំហែមាតុភាព
- ប្រាក់ឧបត្ថម្ភបេសកកម្មក្នុង និងក្រៅប្រទេស
- ប្រាក់ឧបត្ថម្ភមុខតំណែង
- ប្រាក់បុព្វលាភសម្រាប់បុណ្យចូលឆ្នាំប្រពៃណី និងបុណ្យភ្ជុំបិណ្ឌ
- ប្រាក់រំលឹកអតីតភាពការងារ
- ប្រាក់កម្ចីបុគ្គលិកក្នុងអត្រាការប្រាក់សមរម្យ
- ធានារ៉ាប់រងលើហានិភ័យការងារ
- ការតម្លើងប្រាក់បៀវត្សប្រចាំឆ្នាំ
- ធានារ៉ាប់រងលើសេវាថែទាំសុខភាព និងហានិភ័យការងារ
- ធានារ៉ាប់រងលើអាយុជីវិត
- ប្រាក់សោហ៊ុយធ្វើដំណើរ
- អត្ថប្រយោជន៍ផ្សេងៗជាច្រើនទៀត តាមគោលការណ៍កំណត់

## ឯកសារភ្ជាប់ និងការទំនាក់ទំនង

ពាក្យសុំបម្រើការងារចែកជូនដោយ***ឥតគិតថ្លៃ*** នៅការិយាល័យកណ្តាល គ្រប់បណ្តាសាខាទូទាំងខេត្តក្រុង និងគេហទំព័ររបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មហានគរ ម.ក ដោយភ្ជាប់មកជាមួយនូវឯកសារថតចម្លងដូចជា៖ **សញ្ញាបត្រ, អត្តសញ្ញាណប័ណ្ណ ,សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ ប័ណ្ណ-បើកបរ និងលិខិតបញ្ជាក់ផ្សេងៗ ។**

**ការិយាល័យកណ្តាល ៖** អគារលេខ២៤ មហាវិថីយុទ្ធពលខេមរភូមិន្ទ(២៧១) សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

Telephone/Telegram: **087 999 291/ 87 999 221 ឬ E-mail: recruitment@mohanokor.com**

**គេហទំព័រ ៖ www.mohanokor.com , គេហទំព័រសង្គម(Facebook) ៖ Mohanokor Microfinance Institution Plc.**

*សូមអរគុណ!*